00865068

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 26 / 11 / 2012
ម៉ោង (Time/Heure) : 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E236/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២

**ជូនចំពោះ:** ភាគីនៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន, ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង, និងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ

**កម្មវត្ថុ:** ការប្រកាសអំពីសាក្សីដែលគ្រោងផ្តល់សក្ខីកម្មនាពេលខាងមុខ

បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថាជនជាប់ចោទ អៀង សារី មានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ និងបានបង្គាប់ឱ្យគាត់ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតាមមធ្យោបាយសោតទស្សន៍ (ឯកសារ E238/9) នោះ នៅពេលនេះ អង្គជំនុំជម្រះសូមជូនដំណឹងទៅភាគីអំពីសាក្សីទាំងឡាយដែលគ្រោងនឹងផ្តល់សក្ខីកម្មក្នុងសវនាការ នាខែ ធ្នូ និងសវនាការនៅពេលក្រោយៗទៀត។

បន្ទាប់ពីស្តាប់សក្ខីកម្មសាក្សីទាំងឡាយដែលត្រូវបានកំណត់កាលបរិច្ឆេទរួចរាល់ដើម្បីផ្តល់សក្ខីកម្មដែលភាគីបានទទួលការជូនដំណឹងរួចហើយ អង្គជំនុំជម្រះនឹងចាប់ផ្តើមបន្តនូវការស្តាប់សក្ខីកម្មរបស់សាក្សីពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ (ឯកសារ E172/29) ដោយចាប់ផ្តើមពីសាក្សីដែលមានរហស្សនាម TCW-695 និងបន្ទាប់មកទៀតគឺសាក្សីដែលមានរហស្សនាម TCW-398។ បន្ថែមពីលើសាក្សីទាំងឡាយដែលត្រូវបានកំណត់កាលបរិច្ឆេទកាលពីពេលមុនដើម្បីផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធា (ឯកសារ E233) អង្គជំនុំជម្រះនឹង

កោះហៅសាក្សីដែលមានរហស្សនាម TCW-425 (ឯកសារ E172) នៅពេលសមស្របខាងមុខ។ លោក Stephen Heder ក៏នឹងត្រូវកោះហៅឱ្យចូលខ្លួនមកផ្តល់សក្ខីកម្មផងដែរ ដោយពិនិត្យទៅលើឯកសារជាច្រើននៅក្នុងសំណុំរឿង និងឯកសារដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដែលគាត់បានដឹងផ្ទាល់ និង/ឬ គាត់ជាអ្នកនិពន្ធ។

ជាងនេះទៀត អង្គជំនុំជម្រះសាលាដំបូងឯកភាពតាមសំណើរបស់សហព្រះរាជអាជ្ញា (ឯកសារ E236/1/2) ដែលស្នើសុំស្តាប់សក្ខីកម្មរបស់សាក្សីដែលមានរហស្សនាម TCW-161 និង TCW-565 ដោយហេតុថាពួកគាត់ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ហើយការស្តាប់សក្ខីកម្មរបស់ពួកគាត់អាចនាំទៅដល់ការបញ្ជាក់ការពិត។ អង្គជំនុំជម្រះស្នើសុំឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញទាក់ទងទៅសាក្សីទាំងនេះ និងជូនដំណឹងមកអង្គជំនុំជម្រះអំពីលទ្ធភាពដែលពួកគាត់អាចផ្តល់សក្ខីកម្មបាន។

មេធាវីការពារក្តីបានស្នើសុំស្តាប់សក្ខីកម្មរបស់សាក្សី និងអ្នកជំនាញមួយចំនួន (ឯកសារE236)។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាសំណើទាំងនេះ និងឯកភាពតាមសំណើរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន និង នួន ជា ដែលស្នើសុំកោះហៅសាក្សីដែលមានរហស្សនាម TCW-126 និងសាក្សីដែលមានរហស្សនាម TCW-570។ អង្គជំនុំជម្រះនឹងកំណត់កាលបរិច្ឆេទនៃការផ្តល់សក្ខីកម្មរបស់ពួកគាត់នៅពេលសមស្របខាងមុខ។ សេចក្តីសម្រេចនានាពាក់ព័ន្ធនឹងបុគ្គលផ្សេងទៀតដែលភាគីបានស្នើសុំស្តាប់សក្ខីកម្ម និងបុគ្គលដូចដែលបានបង្ហាញរហស្សនាមក្នុងឯកសារ E236 នឹងចេញក្នុងពេលសមស្របខាងមុខ។

ជាចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចពុំស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-35 ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន ដោយហេតុថាអង្គជំនុំ-ជម្រះធ្លាប់បានសម្រេចរួចហើយថាសក្ខីកម្មនេះជារួមគឺច្រំដែលជាមួយភស្តុតាងផ្សេងៗ ដែលបានផ្តល់រួច ឬគ្រោងនឹងផ្តល់នៅចំពោះមុខអង្គជំនុំជម្រះក្នុងពេលឆាប់ៗខាងមុខ។ ប៉ុន្តែភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំកោះហៅដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-35 ក្នុងអំឡុងពេលដែលបានលៃលកទុកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី បង្ហាញភស្តុតាងអំពីទុក្ខវេទនារបស់ពួកគាត់បាន (ឯកសារ E218 កថាខណ្ឌ ១៨)។